# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៧ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២៣/០២២ ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥៥ អនក្រ.បក ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤
- តាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



https://www.moj.gov.kh/kh/law-regular

## សម្រេច

**មាត្រា១ .-**

ត្រូវបានអនុញ្ញាតឱ្យធ្វើការផ្ទេរឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០២៤ | ឥណទានមុនផ្ទេរ | ការផ្ទេរ | | ឥណទានថ្មីក្រោយផ្ទេរ |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | ការផ្ទេរចេញ | | | | 1.100.000 | |
| | ៩៩-ចំណាយមិនទាន់បែងចែក មានមុខសញ្ញា និងចំណាយមិនបានគ្រោងទុក | | | | 1.100.000 | |
| 69 | ចំណាយមិនបានគ្រោងទុក | 2.454.267.000 | 2.396.326.100 | - | 1.100.000 | 2.395.226.100 |
| | ការផ្ទេរចូល | | | 1.100.000 | | |
| | ១០-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | | 600.000 | | |
| 65 | ឧបត្ថម្ភធន (មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្ដាល) | 30.105.000 | 4.386.303.700 | 600.000 | - | 4.386.903.700 |
| | ១២-ក្រសួងសុខាភិបាល | | | 500.000 | | |
| 65 | ឧបត្ថម្ភធន (មន្ទីរពេទ្យជាតិ តេជោសន្តិភាព) | 119.895.000 | 119.895.000 | 500.000 | - | 120.395.000 |

**មាត្រា២ .-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និងអនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់÷

១)-ផ្ដល់ជូនមន្ទីរពេទ្យតេជោសែនកោះធំ ស្ថិតក្រោមមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកណ្ដាលចំនួន **៦០០ លានរៀល** សម្រាប់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងវិសាលភាពនៃការពិនិត្យព្យាបាល ដើម្បីតំឡើងកម្រិតពីមន្ទីរពេទ្យបង្អែកកម្រិត ២ ទៅមន្ទីរពេទ្យបង្អែកកម្រិត ៣។

២)-ផ្ដល់ជូនមន្ទីរពេទ្យជាតិ តេជោសន្តិភាព នៃក្រសួងសុខាភិបាលចំនួន **៥០០ លានរៀល** សម្រាប់ទិញរថយន្ត Pick Up ចំនួន ១ គ្រឿង និងរថយន្ត Van ចំនួន ១ គ្រឿង។



https://www.moj.gov.kh/kh/law-regular

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១០កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



https://www.moj.gov.kh/kh/law-regular